# សម្រង់បណ្តាសាខ្លះៗក្នុងសិលាចារឹកខ្មែរ

## ១- សេចក្តីទូទៅ

**បណ្តាសា** ឬ **ពាក្យផ្តាសា** គឺជាពាក្យពេជន៍ពោលផ្តន្ទា បន់ស្រន់បួងសួងសំបូងសង្រ្វង ប្រទេចផ្តាសាវិនាសហិនហោច[១] តាមបែបជំនឿ ចំពោះទង្វើអាក្រក់ ពុំត្រឹមត្រូវ ពុំលុះតាមសណ្តាប់ ច្បាប់ ឬធម៌។ ការពោលពាក្យផ្តាសា គឺក្នុងបំណងការពារសេចក្តីត្រឹមត្រូវមិនឲ្យបាត់បង់ ឬសេចក្តីត្រឹមត្រូវដែលបាត់បង់ ឲ្យវិលត្រឡប់មកតាមសណ្តាប់ដើមវិញ។ ទំនៀមនេះ មាននៅក្នុងសង្គមខ្មែរតាំងពីដើមដរាបរៀងមកដល់បច្ចុប្បន្ន។ សេចក្តីទាំងនេះ អាចរកឃើញនៅក្នុងសិលាចារឹកជាច្រើនតាំងពីសម័យមុនអង្គរច្រើនចារពាក្យកាព្យតែងលើកសរសើរតម្កើងទេព ព្រះរាជា មន្រ្តីធំៗ ព្រមទាំងអំពើបុណ្យដែរហូតដល់សម័យកណ្តាល។

កម្មវត្ថុសំខាន់និងធំបំផុតនៃការចារសិលាចារឹកជាទូទៅ គឺការកត់ត្រានូវរឿងរ៉ាវជុំវិញអំពើបុណ្យដែលម្ចាស់ទានបានកសាង។ បើពិនិត្យឲ្យទូលាយ ផ្នែកសំស្រ្កឹតដែលភាគលបានកសាង។ ផ្នែកភាសាខ្មែរច្រើនតែកត់អ្វីដែលជាក់ស្តែងជុំវិញព្រឹត្តិការណ៍ទាក់ទងនឹងប្រាសាទដូចជា ការជាវដីថ្វាយប្រាសាទ ថ្វាយដង្វាយផ្សេងៗ, ក្តីក្តាំ ការដោះស្រាយជម្លោះនានាទាក់ទងនឹងប្រាសាទ និងជាពិសេសគឺកត់ត្រានូវរាល់រណ្តាប់បូជាក្នុងកិច្ចពិធីជាដើម[២]។ ដូច្នេះហើយទើបនិយាយដោយខ្លីថាច្រើនតែទាក់ទងនឹងអំពើបុណ្យ។

បុណ្យដែលបានកសាងឡើងហើយជាសមិទ្ធិនានាដូចជា ប្រាសាទ ប្រតិមា ទ្រព្យសម្បត្តិ សត្វពាហនៈ ស្រែចម្ការ វត្ថុប្រើប្រាស់នានា ព្រមទាំងខ្ញុំបម្រើដែលបានថ្វាយចំពោះប្រាសាទ ម្ចាស់ទានរមែងប្រាថ្នាឲ្យបុណ្យនោះគង់វង្សជាអង្វែងដរាបទៅ ពុំមានខូចខាត បាត់បង់ដោយអំពើជាបាបកម្មផ្សេងៗរបស់ជនទាំងពួង។ ឈរលើគំនិតនេះ នៅក្នុងសិលាចារឹករមែងតែងតែមានពាក្យផ្តាសាដល់ជនណាដែលបំផ្លាញឬធ្វើឲ្យខូចខាតនូវបុណ្យឬមូលនិធិសាសនានោះ[៣]។ ទន្ទឹមគ្នានេះដែរ ក៏មានការឲ្យពរ ដើម្បីជម្រុញ លើកទឹកចិត្តអ្នកផងឲ្យមានការថែរក្សាបុណ្យដែលបានសាងនោះ។

---

[១] វចនានុក្រមខ្មែរ, ១ (ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧)។

[២] អាំងជូលាន, មូលដ្ឋានរៀនខ្មែរបុរាណ, យសោធរ (ភ្នំពេញ, ២០១៣), ៨-៩។

[៣] Kunthea Chhom, *Le rôle du sanskrit dans le développement de la langue khmère : Une étude épigraphique du VIe au XIVe siècle* (Sāstrā Publishing House, 2018), 162–63.

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ២- ឥសីវ្យាសៈ និងពាក្យផ្ដាសា

តាមរយៈការសិក្សារបស់បណ្ឌិត ឆោម គន្ធា បានបង្ហាញថាទំនៀមនៃការដាក់បណ្ដាសានិងឲ្យពរនេះ គឺមានប្រភពមកពីឥណ្ឌា តាមរយៈរឿងមហាភារត និងគម្ពីរបុរាណនានា[៦]។ ស្លោកបណ្ដាសាដែលពេញនិយមជាងគេ គឺចេញពីឥសីវ្យាសៈ ដែលជាអ្នកនិពន្ធរឿងមហាភរត គម្ពីរបុរាណ១៨គម្ពីរ និងគម្ពីរព្រហ្មសូត្រ។ មានស្លោក២សំខាន់ដែលឃើញមាននៅក្នុងសិលាចារឹកប្រទេសឥណ្ឌាផង និងនៅប្រទេសកម្ពុជាផង។ ស្លោកទី១ គឺប្រទះឃើញមាននៅក្នុងចារឹកបន្ទះលោហៈ (ឧ. កុមារគុប្ត, ភាវីវម៌ន) ដែលឲ្យពរដល់ផ្ដល់តង្វាយជាដី នឹងបានសោយសុខក្នុងស្ថានសួគ៌អស់កាល៦០០០០ឆ្នាំ ឯអ្នកដណ្ដើមយកដីនោះ នឹងសោយទុក្ខក្នុងនរកអស់កាលដូចគ្នា។ ឯក្នុងសិលាចារឹកខ្មែរវិញ មានក្នុងសិលាចារឹកប្រាសាទអ្នកបួស K. ៣៤១ ផ្ទាំងខាងត្បូង ស.វ.ទី៧ និងសិលាចារឹកវត្តតាំងក្រសាំង ឆ្នាំ៦៦៨[៧]។ ក្នុងសិលាចារឹកប្រាសាទអ្នកបួស នៅសល់តែស្លោកពាក់កណ្ដាលប៉ុណ្ណោះ ខណៈនៅក្នុងសិលាចារឹកវត្តតាំងក្រសាំង គឺនៅសល់ទាំងស្រុង ដែលមានសេចក្ដីដូចនៅឥណ្ឌា។

### សម្រង់អត្ថបទ

បម្ទឹ រ៌សហស្រាណិ ស្វគ្គេ៌ មោទតិ ភូមិទះ
អាច្ឆេត្តា ចានុមន្តា ច តាន្យេវ នរកេ វសេត៑

### សេចក្ដីប្រែសម្រួល

អ្នកឲ្យនូវដី(សោយសុខ)រីករាយនៅស្ថានសួគ៌៦០០០០ឆ្នាំ ឯអ្នកដណ្ដើមយក(ដីនោះ) និងអ្នកញុាំង(ឲ្យដណ្ដើមយកដីនោះ) ក៏នឹងធ្លាក់ទៅក្នុងនរកអស់កាលប៉ុណ្ណោះឆ្នាំដូចគ្នា។

គួរបញ្ជាក់ថា នៅក្នុងរឿងមហាភារត ក្បាលទី១៣ «អនុសាសន៍-បវ៌» ភីស្មៈបានពន្យល់ទៅកាន់យុធិស្ឋិរ ទាំងខ្លួនកំពុងផ្ទុំនៅលើព្រួញដូចជាសយាសនៈនោះ អំពីកាតព្វកិច្ចរាជវង្សនិងសង្គម។ នៅពេលដែលយុធិស្ឋិរលើកសួរថាតើអំណោយណាមួយ គឺជា

[៦] Chhom, *Le rôle du sanskrit dans le développement de la langue khmère : Une étude épigraphique du VIe au XIVe siècle*, 162–95.

[៧] កំ វណ្ណារ៉ា និង អេង សុគង់, ‵សិលាចារឹកវត្តតាំងក្រសាំង ខេត្តកំពង់ធំ′, 24 October 2025, https://khmercivilization.ams.com.kh/detail/33195។

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

បុណ្យដ៏អស្ចារ្យបំផុតនោះ ភីស្មៈមានបន្ទូលថា «ភូមិទាន» គឺការឲ្យនូវដី ជាទានកំពូល ដ្បិតថាដីទ្រទ្រង់នូវការបូជា ការរៀនសូត្រ ប្រាសាទ និងការរស់នៅតជំនាន់ ជាហេតុបង្កើតនូវបុណ្យដែលមិនចេះអស់ (អក្សយបុណ្យ)។ ក្នុងគោលគំនិតនេះ ភីស្មបានលើកពីសម្ដីរបស់ឥសីវ្យាសៈ ដើម្បីបង្ហាញថាជាសក្ខីភាពថា អ្នកឲ្យទានជាដីបានសោយសុខនៅស្ថានសួគ៌៦០០០០ឆ្នាំ ឯអ្នកដែលរឹបអូស ដកហូត ដណ្ដើមយក ឬអ្នកឲ្យដៃប្រព្រឹត្តិអំពើនោះ នឹងត្រូវចុះនរករងទុក្ខ៦០០០០ឆ្នាំដូចគ្នា (មហាភារត, អនុសាសនបវ៌, ជំពូក៦២, ស្លោក៤៧-៤៨)។ ការដាក់បន្ទុកបណ្ដាសាចំពោះជនល្មើស ព្រមទាំងអ្នកឲ្យដៃ គឺជាការពង្រីកលើការទទួលខុសត្រូវផ្នែកសីលធម៌ចំពោះអំណាចស្ថាប័ន ជាពិសេសព្រះមហាក្សត្រនិងមន្ត្រី។

មានស្លោកបណ្ដាសារបស់ឥសីវ្យាសៈ១ទៀត ដែលចាក់ឫសគល់យ៉ាងជ្រៅក្នុងគម្ពីរធម៌សាស្ត្រ ដែលទាក់ទងនឹងទៅច្បាប់ក្នុងការគ្រប់គ្រងនិងសីលធម៌។ ស្លោកទាំងនេះលេចឡើងនៅក្នុងចារឹកលើបន្ទះលោហៈចាប់ពីរាជវង្សគុប្តៈរហូតមក ដែលប្រើសម្រាប់ដាក់ទណ្ឌកម្មដ៏មានឥទ្ធិពលប្រឆាំងនឹងអ្នកបំពានលើមូលនិធិសាសនា ឬដីតង្វាយ។ ដូចស្លោកខាងលើដែរ ស្លោកខាងក្រោមនេះជាបន្ទូលរបស់ភីស្មៈពន្យល់ពាក្យឥសីវ្យាសៈទៅកាន់យុធិស្ឋិរ ស្ដីពីភូមិទាន។

### សម្រង់អត្ថបទ

ស្វទត្តាំ បរទត្តាំ វា យោ ហរេត វាសុន្ធរាម៑
ស វិឞ្ឋាយាំ ក្ឫមិរ៑ ភូត្វា បិត្ឫភិះ សហ បច្យតេ។

### សេចក្ដីប្រែសម្រួល

នរូណាយកដីឲ្យដោយខ្លួនឯងក្ដី ឲ្យដោយអ្នកដទៃក្ដី ក្លាយជាដង្កូវអាចម៍ឆ្កែ និងឆ្អិន(ក្នុងនរក)ព្រមទាំងបិតរគណរបស់គេ។

នៅក្នុងសិលាចារឹកខ្មែរ ស្លោកខាងលើនេះ លេចឡើងក្នុងសិលាចារឹកសម័យមុនអង្គរចំនួន៣ និងសម័យអង្គរ១ផ្ទាំង។ សិលាចារឹក K.៥៥ (គ.ស.៦៦៧) ដែលប្រើល្បៀងពីស្លោកដើមតែបន្តិចប៉ុណ្ណោះ ពោលអាចនិយាយបានថាយកពីឥណ្ឌាមកប្រើទាំងស្រុង។ សិលាចារឹកមួយទៀត គឺសិលាចារឹក K.៧២៦ (ស.វ.ទី៨) ដែលស្រង់យកស្លោកពាក់កណ្ដាលមកប្រើប្រាស់ និងពាក់កណ្ដាលទៀតបង្ហាញច្បាស់ថាធ្លាក់ក្នុងនរកអវិចីដូចមានសេចក្ដី

ថា «នរណាយកដីឲ្យដោយខ្លួនឯងក្ដី ឲ្យដោយអ្នកដទៃក្ដី នរនោះនឹងកើតក្នុងនរកអវិចី មួយអន្ទើដោយបិតរគណនិងញាតិទាំងឡាយរបស់គេ»។ មួយទៀត គឺសិលាចារឹកត្រពាំងក្រមល់ K. ៣៧៨ (ស.វ.ទី១០) ដែលនៅពាក់កណ្ដាលស្លោកទី២ បង្ហាញថាត្រូវរងបាបកម្មចំនួន១០០០០០ឆ្នាំ៖ «នរណាយកដីឲ្យដោយខ្លួនឯងក្ដី ឬឲ្យដោយអ្នកដទៃក្ដី នរនោះនឹងរកអំពើបាបរាប់រយពាន់ឆ្នាំ»។

មានសិលាចារឹកសម័យមុនអង្គរតែមួយគត់ ដែលចារស្លោកទាំងពីរនេះបញ្ចូលគ្នាក្នុងសិលាចារឹកតែមួយ នោះគឺសិលាចារឹកវត្តតាំងក្រសាំង ខេត្តកំពង់ធំ[៦]។ សិលាចារឹកនេះមានសរុបចំនួន៧ស្លោក ត្រង់ស្លោកទី៦ «ស្វទត្តាំ បរទត្តាំ...» បានដាច់នូវពាក់កណ្ដាលស្លោកនិងស្លោកទី៧ គឺជាស្លោក «ចម្ពឹរប៉េសហស្រាណិ...»។ ក្នុងសិលាចារឹកនេះ ត្រង់ស្លោកទី៨និងទី៩ ក៏ជាពាក្យផ្ដាសាចំពោះអ្នកមានចិត្តបាបចាប់យកគោ ស្រែចម្ការច្បារដំណាំដែលគេថ្វាយទៅប្រាសាទផងដែរ។

### សម្រង់អត្ថបទ[៧]

ហត៌ុម៑ ឥច្ឆន្តិ គោក្សេត្រំ ចាបិឞ្ឋាះ ចាបវុទ្ធយះ
អវីចិនរកំ ឃោរម៑ បច្យន្តេ បិតួភិស្សហ។
កល្បកោដិសហស្រាណិ កល្បកោដិយុតានិ ច
អវីចិនរកំ ឃោរម៑ បច្យន្តេ ’បិ ចតុយ៌្យុ[គេ]។

### សេចក្ដីប្រែសម្រួល[៨]

ពួកជនមានចិត្តបាបបំផុត ជាបុគ្គលចម្រើនដោយបាប ប្រាថ្នាចាប់យកនូវស្រែចម្ការ និងគោ នឹងត្រូវចម្អិនយ៉ាងឃោរឃៅក្នុងនរកអវិចី ព្រមទាំងបិតរគណរបស់គេ។

អស់កាលរាប់ពាន់កោដិនៃកប្បផង អស់រយៈពេលរាប់ម៉ឺនកោដិនៃកប្បផង សូម្បីក្នុងយុគទាំង៤ នឹងត្រូវចម្អិនយ៉ាងឃោរឃៅក្នុងនរកអវិចី។

[៦] សូមអាន៖ https://khmercivilization.ams.com.kh/detail/33195

[៧] អត្ថបទអំណាននេះ ជាអត្ថបទកាត់ពាក្យសព្ទ និងសម្រួលអំណានក្នុងអត្ថបទ៖ https://khmercivilization.ams.com.kh/detail/33195

[៨] សេចក្ដីប្រែសម្រួលនេះ បានកែសម្រួលសេចក្ដីខ្លះផ្សេងពីអត្ថបទ៖ https://khmercivilization.ams.com.kh/detail/33195 ដោយសារការផ្ទៀងផ្ទាត់អំណានឡើងវិញ នាំឲ្យមានការប្រែសេចក្ដីផ្សេងដោយអន្ទើ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ៣- សម្រង់សិលាចារឹកបណ្ដាសាមួយចំនួន

ខាងក្រោមនេះជាសម្រង់ឃ្លាជាបណ្ដាសាទាំងក្នុងសិលាចារឹក និងសិលាចារឹកខ្មែរ ដែលមាននៅក្នុងសិលាចារឹកមួយចំនួន។

### សម្រង់អត្ថបទប្រាសាទប្រាំ K.១៥១៣ ឆ្នាំ៦៨៦ [៩]

ឆ្មចាផ្ទាំលង្ឃ្យយ(ន្តិ យេ) ឥល្ហិតាស្តេ ់បិ គោមតះ
កច្ឆន្តិ នរកានិ ប្រេត្យ- រៅរវាគិនគេមតះ។

### សេចក្ដីប្រែសម្រួល

ជនទាំងឡាយណាល្មើសនូវព្រះរាជអាជ្ញា ទោះបីត្រូវបានសរុបកាត់ក្ដីពីទោស(ក្នុងកាលមានជីវិតរួច)ហើយក្ដី ក៏បន្ទាប់ពីជនទាំងឡាយស្លាប់ទៅ ទៅធ្លាក់កាន់នរកទាំងឡាយមាន***រៅរវៈ***ជាអាទិ៍។

### សម្រង់អត្ថបទប្រាសាទភ្នំបាយ៉ង់ K.១២៣៩ ឆ្នាំ៦៦២[១០]

យច្ឆត្តមស្នេធាសាជិ តេជាប្យបហរន្តិយេ
តេយាន្ត្វវីចីនរកា មិ អតិជីត្ស៊ំសភាន្វភះ។

### សេចក្ដីប្រែសម្រួល

ជនទាំងឡាយណាដែលលួចយកខ្ញុំបម្រើក្ដីជាដើម ដែលបានថ្វាយហើយចំពោះ(ប្រតិមា) ជនទាំងឡាយនោះនឹងធ្លាក់ទៅនរកអវិចីព្រមទាំងញាតិពន្ធុអស់កាលដ៏អង្វែង។

### សម្រង់អត្ថបទប្រាសាទល្បៀងព្រះ K.១២៥០ ស.វ.ទី៧[១១]

ហរន្តិ ធា(សា)ជិ និស្ទម្តមស្នេ យេ ត្រីប្រិយាគេត្វរកង្គ្ករាយ
តេ ចាបក្វាស្សហ រន្តុវក្តែ ស្សមាសហស្រន្និរយេ បតន្តុ។

### សេចក្ដីប្រែសម្រួល

ជនទាំងឡាយណាដែលចាប់យកខ្ញុំបម្រើជាដើម ដែលបានថ្វាយចំពោះព្រះអង្គ(គឺ)ព្រះស្រីប្រយាគេស្វរសង្ករ សូមជនទាំងឡាយដែលភ្ញៀវក្នុងអំពើបាប ធ្លាក់ទៅក្នុងនរក១០០០ឆ្នាំ ព្រមទាំងក្រុមញាតិពន្ធុ។

---

[៩] សូមអាន៖ https://khmercivilization.ams.com.kh/detail/33405

[១០] សូមអាន៖ https://dharmalekha.info/texts/INSCIK01239

[១១] សូមអាន៖ https://dharmalekha.info/texts/INSCIK01250

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

### សម្រង់អត្ថបទប្រាសាទព្រៃថ្នល់ខាងត្បូង K.៤៥១ មេទ្វារខាងជើង ឆ្នាំ៦៨០[១២]

[...] កេតនជីសកិតិមាសិវ្រៈ (២) ប្រកិលង្កៅសំរិតចង្កេកិស្រែជំរិជីត្នុរិកេតនជី សកិតិកេតន (៣) ជីស្វំនោជីអ្នក្កាត្វេវិបត្តិវ្រៈកម្រតាជីអញ្ញត្រីកោជាវេក្វរពោះ (៤) - (ជៅ)និរយិស្ថានអ្វីកេតសិកេតកានិតៃអ្មេកេអ្កាកេកោនិចៅកេត (៥) ចាជី–មុតវ្រៈចៅ លហិកាង្ក្ដេលហិកុលេសំរ្យវហារលហិក្ដុំតក្និត្វេ (៦) មុតិវ្រៈលហាកតិប្រែតេត្វេជីអំរិ លហិតិមហានិរយនិវន្ធេវម៉ា [...]

### សេចក្ដីប្រែសម្រួល

[...] នរណាដែលលួចមាសព្រះ ប្រាក់ ស្ពាន់ សំរិត សម្លៀក ស្រែ ច្បារទ្រើង គោ គឺ អ្នកដែលលួច អ្នកសុំ និងអ្នកធ្វើវិបត្តិចំពោះព្រះគម្តែងអញស្រីកេទារេស្វរ អ្នកទាំងនោះ ត្រូវធ្លាក់ទៅស្ថាននរក រួមទាំងជីដូនជីតាគេ អ្នកទាំងប្រុសទាំងស្រី ម្ដាយគេ ឪពុកគេ កូន ចៅគេ។ អ្នកដែលបំបាំងអ្នកដែលបំផ្លាញទាំងនោះ ទាំងចៅក្ដី ប្រពន្ធក្ដី ក្រុមគ្រួសារគេក្ដី ដែលរួមក្ដីក្ដាំក្ដី អ្នកបម្រើក្ដីដែលបំផ្លាញព្រះ សូមឱ្យអ្នកទាំងនោះធ្លាក់ទៅមហានរក។

### សម្រង់អត្ថបទសិលាចារឹកត្រពាំងប្រី K.១២៧ ឆ្នាំ៦២៨-៦២៩[១៣]

កេតត្វេវិប្តត្តិរសប្តបិតាសប្ត (២១) មាតាបញ្ចមហារោវនរកោះបតន្តិ។

### សេចក្ដីប្រែសម្រួល

នរណាដែលបង្កវិបត្តិ (សូមឲ្យញាតិ)៧ជំនាន់ខាងឪពុក ៧ជំនាន់ខាងម្ដាយធ្លាក់ ក្នុងនរកមហារោរវទាំងប្រាំ។

### សម្រង់អត្ថបទសិលាចារឹកភូមិកំរៀង K.១៥៤ ឆ្នាំ៧៣៤

ផ្ទាំងក៖ [...]ជៅកេតរាំឱយិតិ (១៧) កេតឧបិតិតសតិតិសប្តមាតាសប្តបិតានិរ យអតិ (១៨) រោវរកេជៅតតិព្រហ្មត្យាកេមានិតិ

ផ្ទាំងខ៖ [...] ជៅកេតរាំឱយិតិ (១៣) កេតឧបិតិកេតសកិតិសប្តមាតាសប្តបិតា កេជៅនិរយ (១៤) អតិរោវរ[វ]មហារោវរព្រហ្មត្យាផលកេមានិតិ

### សេចក្ដីប្រែសម្រួល

ផ្ទាំងក៖ នៅអ្នកដែលពុំឲ្យ(/បរិច្ចាគ)នៅទីនេះ អ្នកដែលទប់(អ្នកដទៃមិនឲ្យមក បរិច្ចាគ) អ្នកដែលលួចយក គឺ(ញាតិទាំង)៧សន្តានខាងម្ដាយ (ញាតិទាំង)៧សន្តានខាង ឪពុករបស់គេ ធ្លាក់ទៅនរកអតិរោរវ (គឺ)គេធ្លាក់ទៅ(នរក)ដូចទោសសម្លាប់ព្រាហ្មណ៍។

---

[១២] សូមអាន៖ https://khmercivilization.ams.com.kh/detail/28868

[១៣] សូមអាន៖ https://khmercivilization.ams.com.kh/detail/23849

ផ្ទាំងខ៖ នៅអ្នកដែលពុំឲ្យ(/បរិច្ចាគ)នៅទីនេះ អ្នកដែលទប់(អ្នកដទៃមិនឲ្យមកបរិច្ចាគ) អ្នកដែលលួចយក គឺ(ញាតិទាំង)៧សន្តានខាងម្តាយ (ញាតិទាំង)៧សន្តានខាងឪពុករបស់គេ ធ្លាក់ទៅនរកអតិរោរព មហារោរព (គឺ)គេធ្លាក់ទៅ(នរក)ដូចផលនៃទោសសម្លាប់ព្រាហ្មណ៍។

### សម្រង់អត្ថបទសិលាចារឹកបាសាក់ K.៧០ ស.វ.ទី១០

ផ្ទាំងខ៖ [...] ទៅវ្រទ្រវ្យមនិម្រតាញស្រីន្ទ្របេន្ទ្រា (៤) យុធជូន្តវ្រះកម្រតេងអញស្រីន្ទ្រ (៥) បេន្ទ្រាយុធស្វា[មិ] • មាសប្រាក់ជាតុត (៦) ទៃតិតំរ៉េយ្សេះក្របិខ្ញុំស្រុកស្រែ (៧) ភូម្យាករទ្រវ្យទោងី ទៅតេលោបេ (៨) យនេះទ្រវ្យតរោះហានេះហាបិវ្វំធ្វេ (៩) បូជារោះហាកល្ប[ជា យជមា]នតេទៅ (១០) តរេះនរកាតងំនេប្រោវវអំរលិឧបិ (១១) តរតតបិភ្វត្តទៅក្រោយតតបិភ្វត្តទៅ (១២) វ្រស្ថិយាវត្តវ្រះចន្ទ្រាជិត្យត្រហាន (១៣) ក្សត្រកាមានលេយ [...]

### សេចក្តីប្រែសម្រួល

នៅទ្រព្យទាំងឡាយដែលម្រតាញស្រីន្ទ្របេន្ទ្រាយុធជូនចំពោះព្រះកម្តែងអញស្រីន្ទ្របេន្ទ្រាយុធស្វាមី (មាន) មាស ប្រាក់ (លោហ)ជាតុដទៃទៀត ដំរី សេះ ក្របី គោ ខ្ញុំបម្រើ ស្រុកស្រែ ភូម្យាករផង។ នៅអ្នកដែលបំផ្លាញទ្រព្យទាំងអស់នេះ (និង)ពុំធ្វើតាមវណ្ដាប់បូជារបស់ម្ចាស់ទាន អ្នកនោះធ្លាក់ទៅនរកមាននរករោរព ក្រៃលែងនូវបិតរគណ១០តំណរទៅក្រោយ ១០តំណរទៅមុខ ដរាបណាព្រះចន្ទ្រ ព្រះអាទិត្យ គ្រោះ(ភព) នក្សត្រ មាននៅឡើយ។

### សម្រង់អត្ថបទសិលាចារឹកប៉ាលហាល K.៤៤៩ ឆ្នាំ១០៦៩

ផ្ទាំងខ៖ [...] នេះតិរោះប្រតិម្ពាអញតឧចាយនេះឧហាយោបិអ្នកត្តប្រភូតបិវ្វំធ្វេរោះហាប្រតិម្ពានេះទៅអំចាលិ (២៧) ចាបិអ្នកត្តរាជទ្រោហាគុរុទ្រោហិចាបអ្នកត្តសំលាបិព្រាហ្មនអ្មេវប្បាវ្រះគោកបិលលេង៍អ្នកិនោះតិតមានិចាប (២៨) នោះតវិរអ្នកិនោះទៅត្យក្តនរកតងំនេប្រ[អ]វីចិអតិរោវវតភាបិចន្ទ្រាជិត្យលេយ [...]

### សេចក្តីប្រែសម្រួល

នេះគឺការប្រតិស្ថាន(វណ្ដាប់បូជា)របស់អញខ្ញុំដ៏ជាអម្រស់អម្រទាំង(អម្បាល)នេះ ទោះយោបីអ្នកដ៏ជាម្ចាស់ក្តីពុំ ធ្វើតាមការប្រតិស្ថាននេះ នៅអម្បាលបាប(ទាំងឡាយ) ដូចជាទ្រុស្តព្រះរាជា ទ្រុស្តគ្រូ បាបដូចជាសម្លាប់ព្រាហ្មណ៍ ម្តាយ ឪពុក ព្រះគោកបិល សូម

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ឲ្យអ្នកទាំងឡាយនោះ គឺអ្នកដ៏មានបាបនោះ សរីរអ្នកនោះទៅដេក(ត្រាំត្អិន)ក្នុងនរក មាននរកអវិចី អតិរៅរពជាដើម ដរាបណាព្រះចន្ទ្រ និងព្រះអាទិត្យនៅតែមាននៅឡើយ។

**សម្រង់អត្ថបទសិលាចារឹកគោកប្រដាក K.៨៧៨ ចុងស.វ.ទី១០-ស.វ.ទី១១**[១៨]

[…]◦នៅអង (១៨) ក្តរ្វំថ្ងេពេះកល្បនោះគេនៅតនរកសប្តបុរុអាន្តរយាវតិចន្ទ្រ ជិត្យមាន៎

**សេចក្ដីប្រែសម្រួល**

នូវអ្នកពុំធ្វើដូចរណ្ដាប់បូជានេះ អ្នកនោះធ្លាក់ទៅនរក៧សន្តាន ដរាបណាព្រះចន្ទ្រ និងព្រះអាទិត្យនៅតែមាន។

នៅក្នុងសិលាចារឹកសម័យកណ្ដាល ពាក្យផ្ដាសាច្រើនតែដាក់ឲ្យធ្លាក់អបាយភូមិ នរកបញ្ចានន្តរិក កុំបីព្រះពុទ្ធទាំងឡាយប្រោសរួច និងត្រូវវន្ទះបាញ់សព្វជាតិកំណើតជាដើម។ ពាក្យផ្ដាសានេះ បង្ហាញពីរបត់នៃជំនឿសាសនាផងដែរ គឺការប្ដូរពីព្រហ្មញ្ញសាសនាមកពុទ្ធសាសនាវិញ។

**សេចក្ដីសម្រួលពីសិលាចារឹកនគរវត្តលេខ១៩ សម័យកណ្ដាល**[១៩]

[…] ប្រោសអាសូសនេះឱ្យរួចជាព្រៃស្វាងព្រះស្រលះជ្រះឥតកំដឹងឡើយ ថាបើនរណាមួយយកអានេះជាខ្ញុំឡើយ ព្រះអម្បាលខ្សាច់កុំបីប្រោសអ្នកនោះឡើយ ទោះយោបីគម្តែងមុខមន្ត្រីឯណាមួយបង្គាប់រើសឱ្យជាខ្ញុំឡើយ ឱ្យទៅត្អិននាចតុរាបាយភូមិនាយសព្វកាលហោង នាមេទងនេះដ្បិតយកប្រាក់តង្វាយព្រះពុំទាន់ស្រឡះឡើយ អ្នកយកប្រាក់បំពេញឱ្យមេនេះរួចរក្សាព្រះហោងថាបើនរណាមួយយកមេនេះជាខ្ញុំឡើយ ឱ្យអ្នកនោះទៅនាបញ្ចានន្តរិកនាយហោង។

---

[១៨] សូមអាន៖ https://khmercivilization.ams.com.kh/detail/25406

[១៩] សូមអាន៖ https://khmercivilization.ams.com.kh/detail/33390

# បញ្ជីឯកសារ


កំ វណ្ណាប៉, និង អេង សុគង់. `សិលាចារឹកវត្តតាំងក្រសាំង ខេត្តកំពង់ធំ´. 24 October 2025. https://khmercivilization.ams.com.kh/detail/33195.

វចនានុក្រមខ្មែរ. ១. ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧។

អាំងជូលាន. មូលដ្ឋានរៀនខ្មែរបុរាណ. យសោធរ. ភ្នំពេញ, ២០១៣។

Chhom, Kunthea. *Le rôle du sanskrit dans le développement de la langue khmère : Une étude épigraphique du VIe au XIVe siècle*. Sāstrā Publishing House, 2018.


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហ៊ិន ឈុនតេង